កម្មវិធីមូលនិធិសមធម៌

Description: បញ្ហាហិរញ្ញវត្ថុគឺជាឧបសគ្គចំបងមួយដែលរារាំងប្រជាជនក្រីក្រក្នុងការមកទទួលសេវាថែទាំសុខភាពជាមូលដ្ឋាន។ គម្រោងមូលនិធិសមធម៌ និងការចេញ---ប្រាក់ឧបត្ថម្ភជំនួសប្រជាជនគឺជាយន្តការមួយរបស់ក្រសួងសុខាភិបាលដែលត្រូវបានទទួលស្គាល់ថាជាគោលការណ៍មួយដ៏មានប្រសិទ្ធិភាពក្នុងការជួយប្រជាជនក្រីក្រឲ្យទទួលបានសេវាសុខាភិបាលសមរម្យព្រមទាំងការពារពួកគេពីភាពក្រីក្រដែលបណ្តាលមកពីការឈឺថ្កាត់។ ក្រោមជំនួយថវិការបស់ក្រសួងសុខាភិបាលអង្គការរ៉ាក់មានលទ្ធភាពក្នុងការអនុវត្តន៍សកម្មភាពរបស់ខ្លួនដើម្បីគាំទ្រប្រជាជនក្រីក្រ។

គោលបំណង

អង្គការរ៉ាក់ចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រតាមរយៈការការពារប្រជាជនក្រីក្រពីការចំណាយប្រាក់ហោប៉ៅដែលមិនចាំបាច់ ព្រមទាំងធ្វើការលើកកម្ពស់ សម្របសម្រួល និងជំរុញការមកទទួលសេវាសុខភាពរបស់ជនក្រីក្រនៅតាមគ្រឹះស្ថានផ្តល់សេវារបស់រដ្ឋ។

អង្គការរ៉ាក់នឹងជួយបង្កើនគុណភាពសេវាសុខាភិបាលសាធារណៈ ដោយដើរតួនាទីជាភាគីទីបីឯករាជ្យ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាជនក្នុងការទទួលសេវាព្យាបាលមួយប្រកបដោយបរិយាកាសអំណោយផល ។

សកម្មភាព

ដើម្បីសម្រួលដល់ប្រជាជនក្រីក្រក្នុងការមកប្រើប្រាស់សេវា អង្គការរ៉ាក់បានបណ្តុះបណ្តាលអាជ្ញាធរដែនដី និងភ្នាក់ងារតាមសហគមន៍ អោយពួកគាត់ចេះធ្វើការកំណត់គ្រួសារក្រីក្រ រួចផ្តល់ប័ណ្ណសមធម៌ដើម្បីអាចទទួលសេវាដោយឥតគិតថ្លៃនៅមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែករដ្ឋ។ គម្រោងរបស់យើង នៅតែបន្តធ្វើការកំណត់អត្តសញ្ញាណដល់ប្រជាជនក្រីក្រក្រោយការព្យាបាល (post-identification) តាមរយៈការសម្ភាសន៍ដោយប្រើប្រាស់កម្រងសំណួររបស់ក្រសួងសុខាភិបាល។ ភ្នាក់ងារភូមិ និងបុគ្គលិកអង្គការរ៉ាក់ បន្តសកម្មភាពអប់រំដល់អ្នកភូមិក្រីក្រ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ពួកគាត់ អំពីសិទ្ធិក្នុងការទទួលបាន និងផលប្រយោជន៍ផ្សេងៗ ពីការប្រើប្រាស់មូលដ្ឋានសុខាភិបាលសាធារណៈ។

ដើម្បីលើកកម្ពស់គុណភាពសេវាសុខាភិបាលសាធារណៈ បុគ្គលិករ៉ាក់ធ្វើការប្រមូលមតិកែលម្អរបស់ប្រជាជនដែលជាអ្នកប្រើប្រាស់សេវា ដោយប្រើប្រាស់តារាងពិន្ទុ និងចូលរួមដោះស្រាយរាល់កង្វល់នានា តាមរយៈកិច្ចប្រជុំពិភាក្សាជាមួយបុគ្គលិកផ្តល់សេវា ដើម្បីរិះរកវិធីបង្កើនគុណភាពសេវា។ លើសពីនេះទៅទៀត បុគ្គលិករ៉ាក់ធ្វើការចុះសួរសុខទុក្ខអ្នកជំងឺដល់ផ្ទះរបស់ពួកគេ ដើម្បីទទួលមតិត្រលប់ និងធានាថាពួកគាត់ទទួលបាននូវអត្ថប្រយោជន៍ផ្សេងៗដូចដែលបានកំណត់ដែលរួមមាន ថ្លៃអាហារ ថ្លៃធ្វើដំណើរ និងថ្លៃឧបត្ថម្ភបុណ្យសពជាដើម។

បច្ចុប្បន្ននេះ អង្គការរ៉ាក់កំពុងអនុវត្តគម្រោងមូលនិធិសមធម៌របស់ខ្លួន នៅក្នុងស្រុកប្រតិបត្តិចំនួន ៨ (ត្បូងឃ្មុំ ពញាក្រែកមេមត់ កំពង់ត្រឡាច កំពង់ឆ្នាំង បរិបូរណ៍ ស្រែអំបិល និងស្មាច់មានជ័យ) ក្នុងខេត្តចំនួនបី (ត្បូងឃ្មុំ កំពង់ឆ្នាំង និងកោះកុង)។